# អង្គការតម្លាភាពកម្ពុជា

## ការប្រកួតប្រជែងរូបថត

## «គណនេយ្យភាពសារពើពន្ធសម្រាប់ការកាត់បន្ថយវិសមភាព»

I. **ប្រធានបទ៖** វត្តមាននៃគម្លាតវិសមភាពនៅក្នុងសង្គម

II. **ជ័យលាភី៖**

អង្គការតម្លាភាពកម្ពុជា នឹងធ្វើការជ្រើសរើសជ័យលាភីរូបថតឆ្នើមចំនួន ១០រូប។

- ៥ ជ័យលាភី សម្រាប់រូបថតដែលល្អបំផុត នឹងទទួលបានថវិកាចំនួន $១៧៥
- ៥ ជ័យលាភី សម្រាប់រូបថតដែលលេចធ្លោជាងគេ នឹងទទួលបានថវិកាចំនួន $១២៥

III. **លក្ខខណ្ឌក្នុងការចូលរួមប្រកួត៖**

- ជាពលរដ្ឋកម្ពុជាដែលមានអាយុចន្លោះពី ១៥ ទៅ ៣០ ឆ្នាំ
- មានទីលំនៅបច្ចុប្បន្នក្នុងប្រទេសកម្ពុជា
- រូបថតអាចជាស្នាដៃបុគ្គល ឬ ស្នាដៃក្រុមដែលមានសមាជិកមិនលើស ២នាក់

IV. **លក្ខខណ្ឌក្នុងការដាក់ពាក្យ៖**

- រូបថតត្រូវតែឆ្លើយតប និងបង្ហាញពីគម្លាតវិសមភាពនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន
- រូបថតត្រូវតែជាស្នាដៃដើម ហើយថតដោយអ្នកចូលរួមផ្ទាល់
- រូបថតត្រូវតែមានចំណងជើងមួយឃ្លាជាភាសាខ្មែរ និងភាសាអង់គ្លេសដែលមានអត្ថន័យពេញលេញ ហើយមានការសម្រាយអត្ថន័យនៃរូបថតជាភាសាខ្មែរ និងអង់គ្លេសមួយកថាខណ្ឌទៀត (ចំណងជើង និងការសម្រាយន័យត្រូវតែឆ្លុះបញ្ចាំងពីអត្ថន័យនៃរូបថត)

- អ្នកថតរូបអាចថតរូបបានគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។ អ្នកថតរូប ត្រូវសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធជាមុនសិនក្នុងករណីថតរូបបុគ្គល ឬ ទ្រព្យសម្បត្តិនរណាម្នាក់ដែលមានជាប់ពាក់ព័ន្ធ និងច្បាប់កម្មសិទ្ធបញ្ញា
- អ្នកថតរូបអាចលាក់បាំងមុខមាត់ពិតរបស់បុគ្គលណាម្នាក់បាន
- រូបថតអាចត្រូវបានកែសម្រួលដោយប្រើកម្មវិធី Adobe PhotoShop, Adobe Illustration និង Adobe LightRoom

## V. របៀបនៃការដាក់ពាក្យ

- រូបថតត្រូវតែជាប្រភេទ JPEG/JPG ដែលមានទំហំមិនលើសពី ៥ Mb និងមិនតូចជាង ១ Mb ហើយគុណភាពនៃរូបថតគឺ HD
- ផ្ញើររូបថត ១សន្លឹក ភ្ជាប់ជាមួយនឹងឯកសារមួយទៀតដែលមាន ចំណងជើង និងការសម្រាយអត្ថន័យនៃរូបថតទាំងពីរភាសា
- ផ្ញើមកកាន់អ៊ីម៉ែល lymengchi@ticambodia.org ដោយមានការប្រាប់នូវព័ត៌មានផ្ទាល់ខ្លួនរបស់ម្ចាស់រូបថតក្នុងសំណើរនៅលើអ៊ីម៉ែលដែលមានដូចជា (ចំណងជើងនៃរូបថត ឈ្មោះអ្នកថតរូប ភេទ ថ្ងៃ/ខែ/ឆ្នាំកំណើត អាស័យដ្ឋានបច្ចុប្បន្ន ស្ថាប័នការងារ ឬសាកលវិទ្យាល័យ លេខទូរស័ព្ទទំនាក់ទំនង អ៊ីម៉ែល និងកិច្ចព្រមព្រាង) តាមទម្រង់ដូចមានបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម៖
  - ឈ្មោះ៖ **ជី លីម៉េង**
  - ភេទ៖ **ប្រុស**
  - ថ្ងៃ/ខែ/ឆ្នាំកំណើត៖ **២៦ ឧសភា ២០២០**
  - អាស័យដ្ឋានបច្ចុប្បន្ន៖ **ភ្នំពេញ**
  - សាកលវិទ្យាល័យ៖ **សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ**
  - លេខទូរស័ព្ទទំនាក់ទំនង៖ **០៧០ ៧៩៩ ៩៩២**
  - អ៊ីម៉ែល៖ lymengchi996@gmail.com
  - កិច្ចព្រមព្រាង៖ ដោយចូលរួមក្នុងការប្រកួតប្រជែងនេះ ខ្ញុំបាទ/នាងខ្ញុំ ព្រមទទួលយកលក្ខខ័ណ្ឌដែលមានចែងក្នុងទំរង់ពាក្យស្នើសុំ និងយល់ព្រមអនុ

ឡោមតាមការសម្រេចចិត្តចុងក្រោយរបស់គណៈកម្មាធិការវាយតម្លៃ និង ដាក់ពិន្ទុ ដោយមិនមាននូវការជំទាស់តវាផ្សេងៗ

## VI. កំណត់សម្គាល់

- អ្នកថតរូបអាចផ្ញើរូបថតបានតែម្តងប៉ុណ្ណោះ (ការផ្ញើរូបថតទ្វេដងនឹងមិនត្រូវបានពិចារណាសម្រាប់រូបថតទី២)
- អ្នកថតរូបត្រូវទទួលខុសត្រូវចំពោះការអភិវឌ្ឍគំនិត ទីកន្លែងថតរូប និងសំភារៈចាំបាច់ដែលត្រូវប្រើសម្រាប់ការថតរូប
- អ្នកថតរូបត្រូវទទួលខុសត្រូវក្នុងផ្លូវច្បាប់លើរូបថតដែលមានជាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា
- អង្គការតម្លាភាពកម្ពុជារក្សាសិទ្ធិក្នុងការប្រើប្រាស់រូបថតដែលទទួលបានជ័យលាភី ឬ មិនទទួលបានជ័យលាភីក្នុងកម្មវិធីប្រកួតសម្រាប់ការប្រើប្រាស់ និងផ្សព្វផ្សាយបន្ត
- អ្នកថតរូបត្រូវតែបំពេញគ្រប់លក្ខណ្ឌខាងលើ និងរូបថតដែលគោរពតាមទ្រង់ទ្រាយដូចបានបញ្ជាក់នៅខាងលើនេះ ទើបត្រូវបានទទួលយកមកពិចារណា។

## VII. លក្ខន្តិកក្នុងការវិនិច្ឆ័យជ្រើសរើស

- ភាពដើមនៃរូបថត ១០%
- គុណភាពនៃរូបថត ១៥%
- ការធ្វើបទបង្ហាញនៃរូបថត ១៥%
- ភាពច្នៃប្រឌិតនៃរូបថត ២០%
- អត្ថន័យនៃរូបថត ៤០%